LONGBEACH COMMUNITY DEVELOPMENT

CITY OF LONG BEACH · CALIFORNIA · INCORPORATED 1897

**សេចក្ដីជូនដំណឹងជាសាធារណៈ**

# សេចក្ដីជូនដំណឹងអំពីឯកសារផ្ដល់ជូនជាសាធារណៈ

រយៈពេល ១៥ ថ្ងៃសម្រាប់ស្ដាប់មតិសាធារណជន ជុំវិញការពិនិត្យមើលឡើងវិញសេចក្ដីព្រាងនៃរបាយការណ៍រួមប្រចាំឆ្នាំ ស្ដីពីការបំពេញការងារ និងវាយតម្លៃ (CAPER) លើសកម្មភាព និងកម្មវិធីដែលបានទទួលថវិកាជំនួយពីនាយកដ្ឋានលំនៅឋាន និងការអភិវឌ្ឍទីក្រុងរបស់សហរដ្ឋអាមេរិក (HUD), ថវិកាសម្រាប់ទុកសម្រាប់ការអភិវឌ្ឍសហគមន៍ (CDBG), កម្មវិធីភាពជាដៃគូក្នុងការវិនិយោគផ្នែកលំនៅឋាន (HOME) និងថវិកាជំនួយដំណោះស្រាយគ្រាមានអាសន្ន (ESG), នឹងបើកពីថ្ងៃទី ០៤ ខែ ធ្នូ ដល់ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២៤។ កម្មវិធី CAPER នេះវាយតម្លៃវឌ្ឍនភាពរបស់សាលាក្រុង និងប្រសិទ្ធភាពនៃការបំពេញការងាររបស់ខ្លួនក្នុងឆ្នាំសារពើពន្ធ ២០២៣-២០២៤ ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្ររួម និងគោលបំណង និងចំណុចអាទិភាពទាំងឡាយដូចមាននៅក្នុងការរៀបរាប់ក្នុងផែនការរួមសម្រាប់ឆ្នាំសារពើពន្ធ ២០២៣-២០២៧។ សាលាក្រុងនឹងដាក់របាយការណ៍នេះ ទៅជូននាយកដ្ឋានលំនៅឋាន HUD នៅមុនថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២៤។

របាយការណ៍ព្រាងនេះ អាចទាញយកបានពីផ្នែក “Stay Informed: Latest News” នៃគេហទំព័ររបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ក្រុងឡុងប៊ិចតាម៖ longbeach.gov/lbcd, ឬមកយកដោយផ្ទាល់នៅអគារ 411 W. Ocean Blvd., Long Beach, CA 90802 ឬទាក់ទងអ្នកស្រី Elizabeth Weithers តាមអ៊ីម៉ែលនេះ៖ Elizabeth.Weithers@longbeach.gov ឬទូរស័ព្ទទៅកាន់លេខនេះ៖ (562) 570-6912។

បងប្រជាពលរដ្ឋក្រុងឡុងប៊ិច ដែលចង់ផ្ដល់មតិជាលាយលក្ខណ៍អក្សរ ត្រូវដាក់មតិនោះឲ្យបានត្រឹមថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២៤។ បងប្អូនអាចសរសេរមតិនេះ ផ្ញើទៅជូនអ្នកស្រី Elizabeth Weithers Community Development Department, 411 West Ocean Boulevard, Third Floor, Long Beach, California 90802។ អ៊ីម៉ែល៖ Elizabeth.Weithers@longbeach.gov.

សាលាក្រុងឡុប៊ិចមានបំណង ផ្ដល់ការសម្របសម្រួលសមស្របសម្រាប់បងប្អូនជនពិការ ឲ្យស្របតាមច្បាប់ស្ដីពីជនពិការអាមេរិក (ADA) ឆ្នាំ ១៩៩០។ បើបងប្អូនត្រូវការការសម្របសម្រួលពិសេសណាមួយសម្រាប់ជនពិការ ឬស្នើសុំបកប្រែឯកសារ សូមទូរស័ព្ទទៅកាន់អ្នកស្រី Elizabeth Weithers តាមលេខនេះ៖ (562) 570-6912 ឲ្យបានយ៉ាងហោចណាស់ ៤៨ ម៉ោង មុនផុតរយៈពេលទទួលមតិសាធារណជននោះ។ សម្រាប់បងប្អូនដែលមានបញ្ហាស្ដាប់មិនឮ ឬបញ្ហានិយាយមិនរួច សូមទូរស័ព្ទទៅលេខ ៧១១ ដើម្បីគេភ្ជាប់ទៅសេវាទូរគមនាគមន៍បញ្ជូនបន្ត។

បងប្អូនអាចស្នើសុំព័ត៌មាននេះ ជាទម្រង់ផ្សេងពីនេះ ឬស្នើសុំឲ្យមានការសម្របសម្រួលសមស្របណាមួយ សម្រាប់ជនពិការ។ សូមបងប្អូនទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ តាមគេហទំព័រនេះ៖ longbeach.gov/lbcd ឬទូរស័ព្ទនេះ៖ 562.570.3807។ បើបងប្អូនដាក់សំណើ សូមដាក់វាឲ្យបានយ៉ាងតិចបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីយើងខ្ញុំធានាដោះស្រាយជូនតាមសំណូមពរ។ ទោះជាយ៉ាងនេះក្ដី យើងនឹងប្រឹងប្រែងឆ្លើយតបតាមសំណូមពរ ទោះដាក់យឺតជាងពេលនេះ។